**United States Department of Education Office for Civil Rights**

# ទម្រង់ពាក្យបណ្តឹងអំពីការរើសអើង

**អ្នកមិនចាំបាច់ប្រើទម្រង់នេះដើម្បីដាក់ពាក្យបណ្តឹងជាមួយការិយាល័យសម្រាប់សិទ្ធិពលរដ្ឋ** (OCR) **នៃក្រសួងអប់រំស.រ. អ។ អ្នកអាចផ្ញើសំបុត្រ ឬអ៊ីមែលទៅ** OCR **ជំនួសឱ្យទម្រង់នេះ ប៉ុន្តែសំបុត្រ ឬអ៊ីមែលត្រូវតែបញ្ចូលព័ត៌មាននៅក្នុងចំណុច** 1-15 **នៃទម្រង់នេះ។ ប្រសិនបើអ្នកសម្រេចចិត្តប្រើទម្រង់នេះ សូមវាយបញ្ចូលឬសរសេរឲ្យដិតច្បាស់នូវព័ត៌មានទាំងអស់ និងប្រើប្រាស់**
**ទំព័របន្ថែម ប្រសិនត្រូវការកន្លែងទំនេរបន្ថែមទៀត។ កំណែទម្រង់ដែលអាចបំពេញបានតាមអ៊ីនធឺណិត ដែលអាចដាក់ជូនតាមប្រព័ន្ធអេឡិចត្រូនិច អាចរកបាននៅ៖**
**http://www.ed.gov/about/offices/list/ocr/complaintintro.html**។

មុននឹងបំពេញទម្រង់នេះសូមអានព័ត៌មានទាំងអស់ ដែលមាននៅក្នុងកញ្ចប់ព័ត៌មានដែលភ្ជាប់មកជាមួយរួមមាន៖ ព័ត៌មានអំពីនីតិវិធីដោះស្រាយបណ្តឹងរបស់ OCR ការជូនដំណឹងអំពីការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួន និងទម្រង់ការយល់ព្រម។

ប្រសិនបើអ្នកមានសំណួរអំពីសិទ្ធិពលរដ្ឋ ឬអំពីការដាក់ពាក្យបណ្តឹងមួយ អ្នកអាចទាក់ទងទៅ OCR តាមលេខ 800-421-3481, 800-877-8339 (TTY), OCR@ed.gov, ឬ ដោយការទូរស័ព្ទទៅការិយាល័យអនុវត្តច្បាប់ ដែលបម្រើការនៅតាមរដ្ឋ ឬដែនដីរបស់អ្នក។ ព័ត៌មានទាក់ទងសម្រាប់ការិយាល័យអនុវត្តច្បាប់ត្រូវអាចរកឃើញនៅ៖ https://ocrcas.ed.gov/contact-ocr។

ប្រសិនបើអ្នកមានការពិបាកយល់ភាសាអង់គ្លេស អ្នកអាចស្នើសុំសេវាជំនួយភាសាសម្រាប់ព័ត៌មានអំពីក្រសួងនេះ ដោយមិនគិតថ្លៃដោយទូរស័ព្ទទៅលេខ 1-800- USA-LEARN (1- 800-872-5327) (TTY: 1-800-877-8339) ឬអ៊ីមែលមកយើង៖ Ed.Language.Assistance@ed.gov។ ប្រសិនបើអ្នកជាជនមានពិការភាព អ្នកអាចស្នើសុំជំនួយទាក់ទងនឹងពិការភាព ដោយទាក់ទងទៅ OCR តាមលេខ 800-421-3481, 800-877-8339 (TTY), OCR@ed.gov ឬ ដោយការទូរស័ព្ទទៅការិយាល័យអនុវត្តច្បាប់ ដែលបម្រើការនៅតាមរដ្ឋ ឬដែនដីរបស់អ្នក។ ព័ត៌មានទាក់ទងសម្រាប់ការិយាល័យអនុវត្តច្បាប់អាចរកឃើញនៅ៖ https://ocrcas.ed.gov/contact-ocr។ ដើម្បីស្នើសុំឯកសារនេះក្នុងទម្រង់ផ្សេងទៀតដូចជាភាសាសម្រាប់ជនពិការភ្នែក ឬ តួរអក្សរធំ សូមទាក់ទងក្រសួងតាមលេខ 202-260-0852 ឬ om_eeos@ed.gov។

1. ឈ្មោះរបស់បុគ្គលដាក់បណ្តឹងនេះ៖

**នាមត្រកូល៖**____________________ **នាមខ្លួន៖**__________________**អាសយដ្ឋាន៖**

__________________________________________________________________________

**ទីក្រុង៖**____________________________________________ **រដ្ឋ៖**_______________ **ហ្ស៊ីបកូដ៖**__________________

**លេខទូរស័ព្ទបឋម៖**________________________________ **លេខទូរស័ព្ទផ្សេងទៀត៖**____________________________

**អាសយដ្ឋានអ៊ីមែល៖** ______________________________________________________________

2. ឈ្មោះរបស់បុគ្គលត្រូវបានគេរើសអើង (ប្រសិនបើ**ក្រៅពី**ជនដាក់បណ្ដឹង) ។ ប្រសិនបើបុគ្គលដែលត្រូវបានរើសអើងមានអាយុ 18 ឆ្នាំ ឬចាស់ជាងនេះ យើងនឹងត្រូវការហត្ថលេខារបស់បុគ្គលនោះនៅលើទម្រង់បែបបទបណ្ដឹងនេះ និងទម្រង់ការយល់ព្រម/ការបញ្ចេញព័ត៌មាន មុនពេលយើងអាចបន្តដំណើរនៃបណ្ដឹងនេះ ។ ប្រសិនបើបុគ្គលនោះជាអនីតិជន ហើយអ្នកមិនមានសិទ្ធិអំណាចផ្លូវច្បាប់ ក្នុងការដាក់ពាក្យបណ្ដឹងជំនួសសិស្សទេ ហត្ថលេខារបស់ មាតាបិតា អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ផ្សេងទៀតដែលមានសិទ្ធិអនុញ្ញាតរបស់កុមារគឺត្រូវបានតម្រូវ ។

**នាមត្រកូល៖**________________ **នាមខ្លួន៖**________________

**អាសយដ្ឋាន៖** ________________________________________________

**ទីក្រុង៖**____________________________ **រដ្ឋ៖**__________ **ហ្ស៊ីបកូដ៖**__________

**លេខទូរស័ព្ទបឋម៖**____________________ **លេខទូរស័ព្ទផ្សេងទៀត៖**____________________

**អាសយដ្ឋានអ៊ីមែល៖** ____________________________

3. OCR ស៊ើបអង្កេតការតវ៉ាអំពីការរើសអើងប្រឆាំងនឹងសាលារៀន មហាវិទ្យាល័យ និងសាកលវិទ្យាល័យ ស្ថាប័ន និងទីភ្នាក់ងារដែលទទួលបានមូលនិធិ ឬទម្រង់ជំនួយហិរញ្ញវត្ថុផ្សេងទៀតពីក្រសួងអប់រំសហរដ្ឋអាមេរិក និងប្រឆាំងនឹងស្ថាប័នអប់រំសាធារណៈ និងបណ្ណាល័យដែលស្ថិតក្រោមបទប្បញ្ញត្តិនៃគន្ថីទី II នៃច្បាប់ស្ដីពីពលរដ្ឋអាមេរិកាំងដែលមានពិការភាព។ សូមកំណត់អត្តសញ្ញាណស្ថាប័ន ឬទីភ្នាក់ងារដែលពាក់ព័ន្ធជាមួយការរើសអើងដែលត្រូវបានចោទប្រកាន់។ ប្រសិនបើយើងមិនអាចទទួលបណ្ដឹងរបស់អ្នក យើងនឹងព្យាយាមនឹងបញ្ជូនវាទៅ ទីភ្នាក់ងារត្រឹមត្រូវ ហើយនឹងជម្រាបប្រាប់អ្នកនូវអង្គហេតុ ។

**ឈ្មោះរបស់ស្ថាប័ន៖** ________________________________________

**អាសយដ្ឋាន៖**__________________________________________

**ទីក្រុង**៖__________________________ **រដ្ឋ៖** __________ ហ្ស៊ីប**កូដ៖**__________

**ដីបាំតេម៉ង់/សាលារៀន៖** ____________________________________

4. បទប្បញ្ញត្តិទាំងឡាយដែល OCR អនុវត្ត ហាមឃាត់ការរើសអើងដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ភេទ ពិការភាព ឬអាយុ។ បទប្បញ្ញត្តិទាំងនោះក៏ហាមឃាត់ការសងសឹកចំពោះបុគ្គលដែលអះអាងសិទ្ធិសេរីភាពពីការរើសអើង ។ សូមកំណត់ទុកដូចខាងក្រោម៖

- ការរើសអើងផ្អែកលើពូជសាសន៍ ពណ៌សម្បុរ និងដើមកំណើត រួមមានការខកខានក្នុងការផ្ដល់សិទ្ធិចូលប្រើប្រាស់ ប្រកបដោយអត្ថន័យដល់អ្នកសិក្សាភាសាអង់គ្លេស និងឪពុកម្ដាយ និងអាណាព្យាបាលដែលមានជំនាញភាសាអង់គ្លេសមានកម្រិត ក៏ដូចជាការរើសអើងដោយផ្អែកលើពូជពង្សរូប ឬលក្ខណៈជនជាតិ ឬផ្អែកលើសញ្ជាតិនៅក្នុងប្រទេសដែលមានសាសនាលេចធ្លោ ។

- ការរើសអើងផ្អែកលើភេទ រួមមានការរើសអើងដោយផ្អែកលើលក្ខណៈភេទ ការមានផ្ទៃពោះ ឬស្ថានភាពដែលពាក់ព័ន្ធ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ក៏ដូចជាវិធានស្ដីពីស្ថានភាពមាតាបិតា គ្រួសារ ឬអាពាហ៍ពិពាហ៍ ដែលប្រព្រឹត្តចំពោះមនុស្សខុសគ្នាដោយផ្អែកលើភេទ។

- ការរើសអើងដោយផ្អែកលើពិការភាព រួមមានការរើសអើងចំពោះបុគ្គលដែលមានពិការភាពផ្លូវកាយ ឬផ្លូវចិត្ត ដែលកំណត់យ៉ាងសំខាន់នូវសកម្មភាពជីវិតដ៏សំខាន់ ក៏ដូចជាបុគ្គលដែលមានកំណត់ត្រា ឬត្រូវបានចាត់ទុកថាមានពិការភាព។

- ការរើសអើងដោយផ្អែកលើអាយុ មិនកំណត់ការការពារប្រឆាំងនឹងការរើសអើងចំពោះក្រុមអាយុជាក់លាក់មួយ (ឧទាហរណ៍ មនុស្សដែលមានអាយុលើសពី 40 ឆ្នាំ); ទោះយ៉ាងណាក៏ដោយមានភាពចម្រុះខុសគ្នា

នៃការលើកលែង ចំពោះច្បាប់សហព័ន្ធដែលអាចអនុញ្ញាតឲ្យយកអាយុមកពិចារណា។

- ការសងសឹកសំដៅលើសកម្មភាពដែលបានធ្វើឡើងក្នុងគោលបំណងជ្រៀតជ្រែកសិទ្ធិណាមួយនៅក្រោមច្បាប់ដែលអនុវត្តដោយ OCR ឬដោយសារតែអ្នកបានធ្វើពាក្យបណ្តឹង ផ្តល់សក្ខីកម្ម ឬបានចូលរួមក្នុងលក្ខណៈណាមួយនៅក្នុងដំណើរការរបស់ OCR ។

សូមចង្អុលប្រាប់មូលដ្ឋាននៃពាក្យបណ្តឹង

☐ របស់អ្នក៖ ការរើសអើង **សំអាងទៅលើពូជសាសន៍** (**បញ្ជាក់**)

______________________________

______________________________

______________________________

☐ ការរើសអើង **សំអាងទៅលើពណ៌សម្បុរ** (**បញ្ជាក់**)

______________________________

______________________________

______________________________

☐ ការរើសអើង **សំអាងទៅលើដើមកំណើត** (**បញ្ជាក់**)

______________________________

______________________________

______________________________

☐ ការរើសអើង **សំអាងទៅលើភេទ** (**បញ្ជាក់**)

______________________________

______________________________

______________________________

☐ ការរើសអើង **សំអាងទៅលើពិការភាព** (**បញ្ជាក់**)

______________________________

______________________________

______________________________

☐ ការរើសអើង **សំអាងទៅលើអាយុ** (**បញ្ជាក់**)

______________________________

______________________________

☐ **ការសងសឹកដោយសារតែអ្នកបានដាក់ពាក្យបណ្តឹង ឬបញ្ជាក់សិទ្ធិដែលបានអះអាងផ្សេងនៅក្រោមច្បាប់ដែលអនុវត្តដោយ** OCR (**បញ្ជាក់**)

☐ **ការបំពានលើច្បាប់ស្តីពីសិទ្ធិចូលរួមស្មើគ្នាក្នុងកាយវិទ្យាអាមេរិកាំង** (**បញ្ជាក់**)

5. សូមពណ៌នាប្រាប់អំពីទង្វើរើសអើងត្រូវបានចោទនិមួយៗ។ សម្រាប់សកម្មភាពនីមួយៗ សូមបញ្ចូលកាលបរិច្ឆេទដែលអំពើរើសអើងបានកើតឡើង ឈ្មោះរបស់បុគ្គលម្នាក់ៗដែលពាក់ព័ន្ធ និងមូលហេតុដែលអ្នកជឿថាការរើសអើងគឺដោយសារតែជាតិសាសន៍ ពិការភាព អាយុ ភេទ ។ល។ ក៏សូមផ្តល់ឈ្មោះរបស់បុគ្គលណាម្នាក់ដែលមានវត្តមាននិងបានមើលឃើញទង្វើនៃការរើសអើង។

6. តើអ្នកមានឯកសារឬព័ត៌មានជាលាយលក្ខណ៍អក្សរដែលអ្នកជឿថានឹងជួយយើងឲ្យយល់អំពី ពាក្យបណ្តឹងរបស់អ្នកឬទេ ?
- ☐ ទេ
- ☐ បាទ/ចាស់

ប្រសិនបើមាន សូមពណ៌នាអំពីឯកសារឬព័ត៌មានជាលាយលក្ខណ៍អក្សរដែលអ្នកមាន។

**ប្រសិនបើ** OCR **ស៊ើបអង្កេតពាក្យបណ្តឹងរបស់អ្នក យើងអាចស្នើសុំឱ្យអ្នកផ្តល់ឱ្យយើងនូវធាតុដែលអ្នកបានពិពណ៌នាខាងលើ។**

7. តើកាលបរិច្ឆេទ**ថ្មីថ្មោងបំផុត**ណាមួយដែលត្រូវបានគេរើសអើង?

**កាលបរិច្ឆេទ៖** ______________________________

8. តើកាលបរិច្ឆេទនេះ**លើសពីចំនួន**180 **ថ្ងៃកន្លងមក** អ្នកអាចស្នើសុំការលះបង់ នៃតម្រូវការដាក់ពាក្យ។

☐ ខ្ញុំកំពុងស្នើសុំការលះបង់ពេលវេលា 180 ថ្ងៃសម្រាប់ការដាក់ពាក្យបណ្តឹងនេះ។

សូមពន្យល់ថាហេតុអ្វីបានជាមិនដាក់ពាក្យបណ្តឹងរបស់អ្នកក្នុងរយៈពេល 180 ថ្ងៃ។

______________________________

______________________________

______________________________

9. តើអ្នកបានដាក់តម្អូញអំពីការចោទប្រកាន់ដែលអ្នកលើកឡើងនៅក្នុងពាក្យបណ្តឹងនេះទៅសាលា ស្ថាប័ន ឬអង្គការ ឬទីភ្នាក់ងារផ្សេងទៀតឬទេ?

○ បាន ○ ទេ

ប្រសិនបើអ្នកបានមានតម្អូញអំពីការចោទប្រកាន់ដែលអ្នកលើកឡើងនៅក្នុងពាក្យបណ្តឹងនេះដោយ៖

☐ ដាក់ពាក្យបណ្តឹងផ្ទៃក្នុង ឬប្តឹងឧទ្ធរណ៍ជាមួយសាលា ឬស្ថាប័នរបស់អ្នកឬ ?

☐ ចូលរួមក្នុងនីតិវិធីសាទុក្ខរបស់សាលា ឬស្ថាប័នរបស់អ្នកឬ?

☐ ចូលរួមក្នុងសវនាការតាមដំណើរការត្រឹមត្រូវនៅសាលា ឬស្ថាប័នរបស់អ្នក ឬតាមរយៈអង្គការ ឬទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀតឬ ?

ប្រសិនបើអ្នកឆ្លើយថា**បាទ/ចាសចំពោះសំណួរខាងលើ** សូមពណ៌នាអំពីការចោទប្រកាន់ដែលអ្នកបានលើកមកនៅក្នុងពាក្យបណ្តឹងផ្ទៃក្នុង ឬបណ្តឹងឧទ្ធរណ៍តាមរយៈនីតិវិធីសាទុក្ខរបស់សាលា ឬស្ថាប័នរបស់អ្នក ឬនៅក្នុងសវនាការតាមនីតិវិធីកំណត់ កំណត់កាលបរិច្ឆេទដែលអ្នកបានប្តឹងតវ៉ាអំពីការចោទប្រកាន់ និងទីកន្លែងណា ដែលអ្នកបានធ្វើពាក្យបណ្តឹង ហើយប្រាប់យើងអំពីស្ថានភាពនៃពាក្យបណ្តឹងបណ្តឹងឧទ្ធរណ៍ នីតិវិធីបណ្តឹងសាទុក្ខ ឬសវនាការតាមដំណើរការត្រឹមត្រូវ ។ ប្រសិនបើអាចធ្វើបាន សូមផ្តល់ឱ្យយើងនូវច្បាប់ចម្លងនៃពាក្យបណ្តឹង ឬសាទុក្ខរបស់អ្នក ឬបណ្តឹងឧទ្ធរណ៍ ឬសំណើដំណើរការត្រឹមត្រូវ ហើយប្រសិនបើបានបញ្ចប់ ការសម្រេចនៅក្នុងបញ្ហានេះ ។

______________________________

______________________________

______________________________

10. ប្រសិនបើការចោទប្រកាន់ដែលមាននៅក្នុងពាក្យបណ្ដឹងនេះត្រូវបានដាក់ទៅភ្នាក់ងារសិទ្ធិពលរដ្ឋរបស់សហព័ន្ធ រដ្ឋ ឬក្នុងស្រុកណាមួយ ឬតុលាការសហព័ន្ធ ឬរដ្ឋណាមួយ សូមផ្ដល់ព័ត៌មានលម្អិត និងកាលបរិច្ឆេទ ។ យើងនឹងកំណត់ថាតើវាសមស្របទេក្នុងការស៊ើបអង្កេតពាក្យបណ្ដឹងរបស់អ្នកដោយផ្អែកលើការចោទប្រកាន់ជាក់លាក់នៃពាក្យបណ្ដឹងរបស់អ្នក និងចំណាត់ការដែលធ្វើឡើងដោយភ្នាក់ងារ ឬតុលាការផ្សេងទៀត ។

**ទីភ្នាក់ងារ ឬតុលាការ៖**

________________________________________________

**កាលបរិច្ឆេទដាក់ពាក្យ៖** ________________

**លេខករណី ឬឯកសារយោង៖** ________________________________

**លទ្ធផលនៃការស៊ើបអង្កេត/ការរកឃើញដោយភ្នាក់ងារ ឬ តុលាការ៖**

____________________________________________________________

____________________________________________________________

11. អ្នកមិនចាំបាច់មានមេធាវីម្នាក់ដើម្បីដាក់ពាក្យបណ្ដឹងជាមួយ OCR ទេ ប៉ុន្តែ ប្រសិនបើអ្នកមានមេធាវីម្នាក់វិញបុគ្គលិក OCR គឺតម្រូវឲ្យទាក់ទងដោយផ្ទាល់ជាមួយមេធាវីរបស់អ្នក ។ ប្រសិនបើអ្នកមានមេធាវីតំណាងឲ្យអ្នកក្នុងរឿងនេះ សូមផ្ដល់ព័ត៌មានទំនាក់ទំនងមេធាវី ។

**នាមត្រកូល៖**__________________________ **នាមខ្លួន៖** __________________

**លេខទូរស័ព្ទ៖** ____________________**អ៊ីមែល៖**__________________________

12. ប្រសិនបើយើងមិនអាចទាក់ទងអ្នកនៅផ្ទះ ឬ កន្លែងធ្វើការរបស់អ្នកបានទេ យើងចង់បានឈ្មោះ និងលេខទូរស័ព្ទរបស់អ្នក ផ្សេង (សាច់ញាតិ ឬ មិត្តភ័ក្តិ) ដែលដឹងពីទីកន្លែងនិងពេលណា ដែលយើងអាចទៅដល់អ្នកបាន។ ព័ត៌មាននេះ **គឺមិនតម្រូវឲ្យមានឡើយ** ប៉ុន្តែវានឹងជាជំនួយដល់យើង។

**នាមត្រកូល៖**________________________**នាមខ្លួន៖**__________________

**ទូរស័ព្ទ៖**__________________________**អ៊ីមែល៖**____________________

_

13. **ជម្រើសដើម្បីចូលរួមក្នុងដំណើរការសម្រុះសម្រួលមុនរបស់ OCR**

OCR ផ្ដល់នូវដំណើរការសម្រុះសម្រួលមុនដំបូង ជាឱកាសមួយសម្រាប់អ្នកនិងស្ថាប័នអ្នកទទួល ដើម្បីដោះស្រាយការតវ៉ារបស់អ្នកដោយស្ម័គ្រចិត្តភ្លាមៗបន្ទាប់ពីអ្នកដាក់ពាក្យជាមួយ OCR ។

ការសម្រុះសម្រួលគឺជាទម្រង់នៃការដោះស្រាយបណ្ដឹង ដែល OCR ផ្ដល់ជូនជាជម្រើសមួយសម្រាប់ដំណើរការស៊ើបអង្កេតរបស់ខ្លួន។ ការសម្រុះសម្រួលគឺជាដំណើរការក្រៅផ្លូវការមួយ ដែលបុគ្គលិកមកពី OCR ដែលត្រូវបានបណ្ដុះបណ្ដាលក្នុងការសម្រុះសម្រួលជួយភាគីឱ្យឈានដល់ការចរចាររកដំណោះស្រាយនៃពាក្យបណ្ដឹង។ អ្នកសម្រុះសម្រួលមិនសម្រេចចិត្តថាអ្នកណាត្រូវ ឬខុស ហើយមិនមានសិទ្ធិអំណាចក្នុងការកំណត់ដំណោះស្រាយលើគូភាគីឡើយ ។ ផ្ទុយទៅវិញ អ្នកសម្រុះសម្រួលជួយភាគីឱ្យស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមកចំពោះពាក្យបណ្ដឹងរបស់អ្នក។ ការសម្រុះសម្រួលគឺជាដំណើរការដោយស្ម័គ្រចិត្តតែប៉ុណ្ណោះ។ ប្រសិនបើភាគីណាមួយមិនចង់ចូលរួមក្នុងការសម្រុះសម្រួល OCR នឹងដោះស្រាយពាក្យបណ្ដឹងតាមរយៈដំណើរការធម្មតារបស់ខ្លួន។

*ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងដំណើរការសម្រុះសម្រួលមុនពេល អ្នកត្រូវតែគូសក្នុងប្រអប់ខាងក្រោម ។* ប្រសិនបើអ្នកបង្ហាញពីចំណាប់អារម្មណ៍របស់អ្នកក្នុងការសម្រុះសម្រួលមុនដំបូងដោយគូសក្នុងប្រអប់ខាងក្រោម **ហើយ** OCR កំណត់ថាពាក្យបណ្តឹងរបស់អ្នកគឺសមរម្យសម្រាប់ដំណើរការនេះ OCR នឹងទាក់ទងអ្នក និងស្ថាប័នអ្នកទទួល ហើយផ្តល់ជម្រើសដំណោះស្រាយនេះ។ ប្រសិនបើអ្នកទទួលយល់ព្រមចូលរួមក្នុងការសម្រុះសម្រួលមុនដំបូង OCR នឹងធ្វើការជាមួយអ្នក និងអ្នកទទួល ដើម្បីសម្រេចបាននូវដំណោះស្រាយដែលយល់ព្រមគ្នាទៅវិញទៅមកនៃពាក្យបណ្តឹងរបស់អ្នក។ ប្រសិនបើអ្នកទទួលមិនមានបំណងចង់ចូលរួមក្នុងការសម្រុះសម្រួលមុនដំបូងទេ OCR នឹងបន្តដំណើរការជាទៀងទាត់នៃពាក្យបណ្តឹងរបស់អ្នក ។ ***ប្រសិនបើអ្នកមិនបង្ហាញពីចំណាប់*** *អារម្មណ៍របស់អ្នកក្នុងការសម្រុះសម្រួលមុនដំបូងដោយគូសក្នុងប្រអប់ខាងក្រោមទេ ការសម្រុះសម្រួលជាមុននឹងមិនត្រូវបានផ្តល់ជូនអ្នកទេ ហើយ* OCR *នឹងបន្តដំណើរការធម្មតានៃពាក្យបណ្តឹងរបស់អ្នក។*

*ខ្ញុំមានចំណាប់អារម្មណ៍ក្នុងការសម្រុះសម្រួលមុនដំបូង (សូមគូសក្នុងប្រអប់)៖* [ ]

14. តើអ្នកចង់ឱ្យស្ថាប័នធ្វើអ្វីជាលទ្ធផលនៃពាក្យបណ្តឹងរបស់អ្នក — តើអ្នកកំពុងស្វែងរកដំណោះស្រាយអ្វី ?

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

15. យើងមិនអាចទទួលពាក្យបណ្តឹងរបស់អ្នកទេ ប្រសិនបើអ្នកមិនបានចុះហត្ថលេខាលើវានោះ។ សូមចុះហត្ថលេខានិងកាលបរិច្ឆេទលើពាក្យបណ្តឹងរបស់អ្នកនៅខាងក្រោម។

| | |
|---|---|
| __________ (កាលបរិច្ឆេទ) | ______________________________ (ហត្ថលេខា) |
| __________ (កាលបរិច្ឆេទ) | ______________________________ (ហត្ថលេខារបស់បុគ្គលក្នុងចំណុចទី 2) |

សូមផ្ញើលិខិត ឬផ្ញើអ៊ីមែលនូវទម្រង់ពាក្យបណ្តឹងអំពីការរើសអើងដែលបានបំពេញ និងចុះហត្ថលេខា ទម្រង់ការយល់ព្រមដែលបានចុះហត្ថលេខារបស់អ្នក និងច្បាប់ចម្លងនៃឯកសារលាយលក្ខណ៍អក្សរ ឬឯកសារផ្សេងទៀតដែលអ្នកជឿថានឹងជួយ OCR យល់ពីពាក្យបណ្តឹងរបស់អ្នកទៅកាន់ការិយាល័យអនុវត្តច្បាប់របស់ OCR ដែលទទួលខុសត្រូវចំពោះរដ្ឋអំពីទីតាំងរបស់ស្ថាប័ន ឬអង្គភាពដែលអ្នកកំពុងមានពាក្យបណ្តឹងនោះ។ អ្នកអាចស្វែងរកព័ត៌មានអាសយដ្ឋានសំបុត្រសម្រាប់ការិយាល័យអនុវត្តច្បាប់ត្រឹមត្រូវនៅលើវេបសាយរបស់ OCR នៅ https://ocrcas.ed.gov/contact-ocr។

**ទម្រង់ការយល់ព្រម - សម្រាប់ការបង្ហាញឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតដែលមាននៅក្នុងទម្រង់ការតវ៉ាអំពីការរើសអើងចំពោះអ្នកផ្សេងទៀត**

(សូមសរសេរឲ្យជិតច្បាស់ ឬវាយបញ្ចូល លើកលែងតែសម្រាប់បន្ទាត់ហត្ថលេខា)

**ឈ្មោះរបស់អ្នក៖** ______________________________

**ឈ្មោះសាលា ឬស្ថាប័នផ្សេងទៀតដែលអ្នកបានដាក់ពាក្យបណ្ដឹងនេះប្រឆាំង៖**______________________________

- គោលបំណងនៃទម្រង់ការយល់ព្រមនេះគឺសម្រាប់ ការិយាល័យសិទ្ធិសម្រាប់ពលរដ្ឋ (OCR) ដើម្បីស្នើសុំការយល់ព្រមរបស់អ្នក ដើម្បីបង្ហាញឈ្មោះរបស់អ្នក និងព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតដែលមាននៅក្នុងទម្រង់បែបបទបណ្ដឹងរើសអើងសម្រាប់ការស៊ើបអង្កេតរបស់ OCR និងសកម្មភាពអនុវត្តដែលទាក់ទងនឹងទម្រង់បណ្ដឹងការរើសអើង។
- ជាឧទាហរណ៍ ដើម្បីសម្រេចថាតើសាលាមានការរើសអើងចំពោះបុគ្គលនោះ OCR ជារឿយៗត្រូវបង្ហាញឈ្មោះរបស់បុគ្គលនោះ និងព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតពីការតវ៉ារបស់ពួកគេទៅកាន់បុគ្គលិកនៅសាលានោះ ដើម្បីផ្ទៀងផ្ទាត់ការពិត ឬទទួលបានព័ត៌មានបន្ថែម។ ពេលដែល OCR ធ្វើដូច្នេះ OCR ជូនដំណឹងដល់បុគ្គលិកទាំងនោះថា ការសងសឹកគ្រប់ទម្រង់មកលើបុគ្គលនោះ និងអ្នកដែលពាក់ព័ន្ធជាមួយបុគ្គលនោះត្រូវបានហាមឃាត់។ OCR ក៏អាចបង្ហាញឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលនោះ ក្នុងអំឡុងពេលសម្ភាសន៍ជាមួយសាក្សី និងការពិគ្រោះយោបល់ជាមួយអ្នកជំនាញផងដែរ។
- ប្រសិនបើអ្នកមិនយល់ព្រមឱ្យ OCR បញ្ចេញឈ្មោះរបស់អ្នក ឬព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតដែលមាននៅក្នុងទម្រង់បែបបទបណ្ដឹងអំពីការរើសអើងដូចបានរៀបរាប់ខាងលើទេ OCR អាចសម្រេចចិត្តបិទបណ្ដឹងតវ៉ារបស់អ្នក ប្រសិនបើ OCR កំណត់ថា ចាំបាច់ត្រូវបង្ហាញព័ត៌មានបែបនេះ ដើម្បីកំណត់ថាតើសាលាមានការរើសអើងនឹងអ្នកឬអត់។

  សម្គាល់៖ ប្រសិនបើអ្នកដាក់ពាក្យបណ្ដឹងជាមួយ OCR នោះ OCR អាចបញ្ចេញព័ត៌មានជាក់លាក់អំពីពាក្យបណ្ដឹងរបស់អ្នកទៅកាន់សារព័ត៌មាន ឬសាធារណជនទូទៅ រួមទាំងឈ្មោះសាលា ឬស្ថាប័នផងដែរ; កាលបរិច្ឆេទដែលពាក្យបណ្ដឹងរបស់អ្នកត្រូវបានប្ដឹង; ប្រភេទនៃការរើសអើងរួមបញ្ចូលនៅក្នុងពាក្យបណ្ដឹងរបស់អ្នក; កាលបរិច្ឆេទដែលបណ្ដឹងរបស់អ្នកត្រូវបានដោះស្រាយ ច្រានចោល ឬបិទ; ហេតុផលជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តរបស់ OCR; ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។ ព័ត៌មានណាមួយដែល OCR ចេញផ្សាយដល់សារព័ត៌មាន ឬសាធារណជនទូទៅ នឹងមិនរួមបញ្ចូលឈ្មោះរបស់អ្នក ឬឈ្មោះរបស់មនុស្សដែលអ្នកបានដាក់ពាក្យបណ្ដឹងនោះទេ។

  សម្គាល់៖ OCR តម្រូវឲ្យអ្នកឆ្លើយតបទៅសំណើរសុំព័ត៌មានរបស់ខ្លួន។ ការខកខានចូលសហការជាមួយនឹងសកម្មភាពស៊ើបអង្កេត និងដំណោះស្រាយរបស់ OCR អាចបណ្ដាលឱ្យមានការបិទពាក្យបណ្ដឹងរបស់អ្នក។

### សូមចុះហត្ថលេខាវគ្គ A ឬវគ្គ B (បន្ថែមមិនទាំងពីរឡើយ) ហើយផ្ញើវាត្រឡប់ទៅ OCR វិញ៖

- ប្រសិនបើបានដាក់ពាក្យបណ្ដឹងសម្រាប់រូបអ្នក អ្នកគួរតែចុះហត្ថលេខាលើទម្រង់នេះ។
- ប្រសិនបើបានដាក់ពាក្យបណ្ដឹងក្នុងនាមបុគ្គលជាក់លាក់ណាម្នាក់ផ្សេងទៀត អ្នកនោះគួរតែចុះហត្ថលេខាលើទម្រង់នេះ។

  **ការលើកលែង៖** ប្រសិនបើពាក្យបណ្ដឹងត្រូវបានដាក់ក្នុងនាមបុគ្គលជាក់លាក់ណាម្នាក់ដែលមានអាយុក្រោម 18 ឆ្នាំ ឬមនុស្សពេញវ័យដែលគ្មានសមត្ថភាពស្របច្បាប់ ទម្រង់បែបបទនេះត្រូវតែចុះហត្ថលេខាដោយមាតាបិតា ឬអាណាព្យាបាលស្របច្បាប់របស់បុគ្គលនោះ។
- ប្រសិនបើអ្នកដាក់ពាក្យបណ្ដឹងក្នុងនាមក្រុមមនុស្ស ជាជាងមនុស្សជាក់លាក់ណាមួយ អ្នកគួរតែចុះហត្ថលេខាលើទម្រង់នេះ។

A. **ខ្ញុំផ្ដល់ការយល់ព្រមរបស់ខ្ញុំឱ្យ OCR ក្នុងការបង្ហាញឈ្មោះរបស់ខ្ញុំ (និងកូន/វួដជាអនីតិជនរបស់ខ្ញុំក្នុងនាមបណ្ដឹងនេះ) និងព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតដែលមាននៅក្នុងទម្រង់បែបបទបណ្ដឹងរើសអើងដល់អ្នកដទៃសម្រាប់ការស៊ើបអង្កេតរបស់ OCR និងសកម្មភាពអនុវត្តដែលទាក់ទងនឹង ទម្រង់បណ្ដឹងការរើសអើង។**

______________________________ ______________________________

**ហត្ថលេខា** **កាលបរិច្ឆេទ**

**ឬ**

B. **ខ្ញុំមិនផ្តល់ការយល់ព្រមរបស់ខ្ញុំឱ្យ OCR ក្នុងការបង្ហាញឈ្មោះរបស់ខ្ញុំ** (**និងកូន/វួដជាអនីតិជនរបស់ខ្ញុំក្នុងនាមបណ្តឹងនេះ**) **និងព័ត៌មានផ្ទាល់ខ្លួនផ្សេងទៀតដែលមាននៅក្នុងទម្រង់បែបបទបណ្តឹងរើសអើងដល់អ្នកដទៃសម្រាប់ការស៊ើបអង្កេតរបស់** OCR **និងសកម្មភាពអនុវត្តដែលទាក់ទងនឹងទម្រង់បណ្តឹងការរើសអើងទេ។** ខ្ញុំយល់ ថា OCR ប្រហែលជាបិទពាក្យបណ្តឹងរបស់ខ្ញុំ។

**ហត្ថលេខា** ____________________ **កាលបរិច្ឆេទ** ____________________

ខ្ញុំសូមប្រកាសក្រោមការពិន័យនៃការភូតកុហក ថាវាជាការពិតនិងត្រឹមត្រូវថា ខ្ញុំជាមនុស្សដែលមានឈ្មោះខាងលើ; ហើយប្រសិនបើពាក្យបណ្តឹងត្រូវបានប្តឹងដោយឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ក្នុងនាមអនីតិជន/បុគ្គលដែលត្រូវបានប្រកាសថាគ្មានសមត្ថភាពដោយសារតែអសមត្ថភាពរាងកាយ ឬផ្លូវចិត្ត ឬអាយុ ដោយតុលាការនៃយុត្តាធិការមានសមត្ថកិច្ច ថាខ្ញុំជាឪពុកម្តាយរបស់បុគ្គលនោះ ឬ អាណាព្យាបាលស្របច្បាប់ ។ សេចក្តីប្រកាសនេះផ្តល់ការយល់ព្រមសម្រាប់តែការបង្ហាញអត្តសញ្ញាណរបស់បុគ្គលប៉ុណ្ណោះ (និងព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គលផ្សេងទៀតអំពីពួកគេមាននៅក្នុងទម្រង់បណ្តឹងការរើសអើង) ហើយមិនពង្រីកដល់ការទាមទារណាមួយដែលបានដាក់ក្នុងពាក្យបណ្តឹងនោះទេ។

**ដកស្រង់ចេញពីគេហទំព័រអនឡាញ** ទម្រង់ពាក្យបណ្ដឹងអន្តរកម្ម

ពូជសាសន៍ / ពណ៌សម្បុរ / ដើមកំណើត / ជាតិពន្ធុ / ពូជពង្សរួម

ការរើសអើងផ្អែកលើដើមកំណើត រួមមានការរើសអើងដោយផ្អែកលើប្រទេស តំបន់ពិភពលោក ឬទីកន្លែងដែលបុគ្គល ឬបុព្វបុរសរបស់ពួកគេមកពី; កម្រិតជំនាញភាសាអង់គ្លេសរបស់ បុគ្គលម្នាក់ ឬស្ថានភាពអ្នកសិក្សាភាសាអង់គ្លេស; និង ពូជពង្សរួម ឬលក្ខណៈជនជាតិភាគតិចពិតប្រាកដរបស់បុគ្គលម្នាក់ រួមទាំងសមាជិកភាពក្នុងសាសនាដែលអាចត្រូវបានគេយល់ថា បង្ហាញលក្ខណៈបែបនេះ (ឧ. សិស្សហិណ្ឌូ យូដា មូស្លីម និង ស៊ីក)។ សម្រាប់ព័ត៌មានបន្ថែមអំពីការរើសអើងពូជសាសន៍ ពណ៌សម្បុរ និងដើមកំណើត សូមចូលទៅ www.ed.gov/ocr/frontpage/pro- students/race-origin-pr.html ។

ភេទ

ការរើសអើងផ្អែកលើភេទ រួមមានការរើសអើងដោយផ្អែកលើលក្ខណៈភេទ ការមានផ្ទៃពោះ ឬស្ថានភាពពាក់ព័ន្ធ ទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ ។ ការរើសអើងដោយផ្អែកលើភេទក៏រួមបញ្ចូលវិធានអំពីស្ថានភាពឪពុកម្ដាយ គ្រួសារ ឬអាពាហ៍ពិពាហ៍ដែលប្រព្រឹត្តចំពោះមនុស្សខុសៗគ្នាដោយផ្អែកលើភេទ ។ សម្រាប់ព័ត៌មានបន្ថែមអំពីការរើសអើងខាងភេទសូមចូលទៅ https://www2.ed.gov/policy/rights/guid/ocr/sexoverview.html ។

ពិការភាព

ជនពិការត្រូវបានកំណត់ថាជាជនណាម្នាក់ដែល (i) មានពិការភាពផ្លូវកាយ ឬផ្លូវចិត្ត ដែលកំណត់យ៉ាងសំខាន់នូវសកម្មភាពជីវិតដ៏សំខាន់មួយ ឬច្រើន ឬ (ii) មានកំណត់ត្រានៃការចុះខ្សោយបែបនេះ ឬ (iii) ត្រូវបានចាត់ទុកថាមាន ការចុះខ្សោយបែបនេះ។ ថាតើបុគ្គលម្នាក់មានពិការភាពឬអត់ គឺមិនត្រូវកំណត់ដោយការគិតពីវិធានការកាត់បន្ថយនោះទេ។ សម្រាប់ព័ត៌មានបន្ថែមអំពីការរើសអើងខាងពិការភាព សូមចូល www.ed.gov/policy/rights/guid/ocr/disability.html ។